ក្រុមមេធាវីខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# ការអប់រំ

២០០៧

WWW.CAMLAW.COM.KH

# ព្រះរាជក្រម

នស/រកម/១២០៧/០៣២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអប់រំ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE

# ច្បាប់

# ស្ដីពី

# ការអប់រំ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិ សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព ដែលធានាបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២.- គោលបំណង

ច្បាប់នេះមានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ ។

### មាត្រា ៣.- វិសាលភាពអនុវត្តន៍

ច្បាប់នេះមានវិសាលភាពលើគ្រប់កម្មវិធីអប់រំ សិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ គ្រប់កម្រិតភូមិសិក្សាសាធារណៈ និងឯកជននៃប្រព័ន្ធអប់រំ ទោះជាកម្មវិធីអប់រំនោះ ធ្វើឡើងនៅក្នុងស្ថាប័នអប់រំ ឬ ដោយបុគ្គលិកអប់រំព្រមទាំងគ្របដណ្តប់លើរដ្ឋបាលកិច្ចនិងការគ្រប់គ្រងការអប់រំគ្រប់កម្រិត លើកលែងតែការអប់រំអំពីគម្ពីរសាសនា ការអប់រំខាងបច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខ ការអប់រំខាងផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ការអប់រំដែលផ្តល់ដោយសាលាភូមិន្ទរដ្ឋបាល និងការអប់រំបច្ចេកទេស និង វិជ្ជាជីវៈតុលាការដែលផ្តល់ដោយស្ថាប័នបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈច្បាប់ និងតុលាការ ។

ច្បាប់នេះអនុវត្តផងដែរលើបុគ្គល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដូចជាកុមារដែលស្ថិតក្នុងអាយុត្រូវចូលសិក្សា អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល ក្រុម ឬ ក្លឹបអ្នកសិក្សា និងបុគ្គលិកអប់រំ ព្រមទាំងអ្នកកាន់អាជ្ញាប័ណ្ណអប់រំ និងសិទ្ធិវន្តនៃអាជ្ញាប័ណ្ណអប់រំ លើកលែងចំពោះអ្នកដែលពាក់ព័ន្ធក្នុងការអប់រំ និង ប្រតិបត្តិខាងសាសនា បច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខ ផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ផ្នែកភូមិន្ទរដ្ឋបាល និងផ្នែកវិជ្ជាជីវៈតុលាការ ។

**មាត្រា ៤.- និយមន័យការអប់រំ និងពាក្យសំខាន់ៗ**

ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក ។

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ឧត្តមក្រុមប្រឹក្សាជាតិអប់រំ

**មាត្រា ៥.- ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ**

ត្រូវបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដែលមានភារកិច្ច ៖

-លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល

-វាយតម្លៃការងារ ដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល ។

-កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ

**មាត្រា ៦.- សមាសភាព និង ការរៀបចំ និងការប្រព្រឹត្តទៅ**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងក្នុងចំណោមឥស្សរជនដែលមានបទពិសោធន៍ខាងអប់រំ នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយអនុ-

ROYAUME DU CAMBODGE
REGISTRE DU PALAIS ROYAL

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ មានក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់គុណភាពអប់រំជាលេខាធិការ ។

## ជំពូកទី ៣
## រដ្ឋបាលកិច្ច និងការគ្រប់គ្រងការអប់រំ

**មាត្រា ៧.- ឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងការអប់រំ**

ក្នុងវិស័យអប់រំត្រូវមានឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងការអប់រំ ៤(បួន)ថ្នាក់ រួមមានថ្នាក់ជាតិ ឬ កណ្តាល ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ និងថ្នាក់គ្រឹះស្ថានសិក្សា ។

រចនាសម្ព័ន្ធនៃឋានានុក្រមរដ្ឋបាលនិងការគ្រប់គ្រងការអប់រំ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

**មាត្រា ៨.- ភូមិសិក្សា និងប្រភេទសិក្សា**

ប្រព័ន្ធអប់រំជាតិមាន ៣(បី) ភូមិសិក្សារួមមាន បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ។

ប្រភេទសិក្សាចែកជា ២(ពីរ) ប្រភេទសិក្សាចំណេះដឹងទូទៅ និងប្រភេទសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៩.- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ**

វិស័យអប់រំត្រូវមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃវិស័យអប់រំ ដែលត្រូវបញ្ចូលការត្រួតពិនិត្យតាមដាន អធិការកិច្ច និងសវនកម្មផ្ទៃក្នុងលើការបំពេញការងារ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ មានភារកិច្ចទទួលខុសត្រូវរៀបចំយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃនេះ ។

**មាត្រា ១០.- គ្រឹះស្ថានសិក្សា**

រដ្ឋត្រូវរៀបចំឱ្យមានគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ។

ការគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

**មាត្រា ១១.- ការបង្កើតគ្រឹះស្ថានសិក្សា**

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ ឬ រូបវន្តបុគ្គល មានសិទ្ធិស្នើបង្កើតគ្រឹះស្ថានសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជន តាមប្រភេទគ្រឹះស្ថានសិក្សា ។

ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក និងការប្រែក្លាយគ្រឹះស្ថានសិក្សា ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

គ្រប់គ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលទាំងអស់ត្រូវមានអាជ្ញាប័ណ្ណអប់រំជាមុនទើបមានសិទ្ធិដំណើរការបាន ។

**មាត្រា ១២.- ប្រភេទគ្រឹះស្ថានសិក្សា**

ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវស្របតាមបេសកកម្មអប់រំរបស់ខ្លួន ។

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីការកំណត់ប្រភេទគ្រឹះស្ថានសិក្សា ។

**មាត្រា ១៣.- ស្វ័យភាពនៃគ្រឹះស្ថានសិក្សា**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបានផ្តល់សិទ្ធិជាអង្គភាពមានស្វ័យភាពខាងការគ្រប់គ្រង ។

ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្អែកលើគោលការណ៍ទទួលខុសត្រូវ តម្លាភាព និងប្រយោជន៍សាធារណៈ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវចេញគោលការណ៍ណែនាំអំពីការផ្តល់សិទ្ធិជាអង្គភាពមានស្វ័យភាពក្នុងការគ្រប់គ្រង ។

**មាត្រា ១៤.- ការផ្តល់វិញ្ញាបនបត្រ និងសញ្ញាបត្រ**

វិញ្ញាបនបត្រ ឬ សញ្ញាបត្រ ត្រូវបានផ្តល់ដល់អ្នកសិក្សា ដែលបានបំពេញគ្រប់លក្ខខណ្ឌតម្រូវនៃការសិក្សាដែលកំណត់ដោយគ្រឹះស្ថានសិក្សា ។

វិញ្ញាបនបត្រ ឬ សញ្ញាបត្រអាចត្រូវបានដកហូត ឬ បដិសេធដោយក្រសួង ឬ គ្រឹះស្ថានសិក្សាដែលផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រនោះ ក្នុងករណីត្រូវបានពិនិត្យរកឃើញមាន

ភាពមិនត្រឹមត្រូវក្នុងដំណើរការសិក្សារបស់អ្នកសិក្សា ឬ ភាពមិនត្រឹមត្រូវក្នុងការសម្រេចផ្ដល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រដល់អ្នកសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវចេញគោលការណ៍ស្ដីពីការផ្ដល់ ដកហូត ឬ បដិសេធវិញ្ញាបនបត្រ ឬ សញ្ញាបត្រដល់អ្នកសិក្សា ។

## ជំពូកទី ៤
## ប្រព័ន្ធអប់រំ

### មាត្រា ១៥.‒ ប្រព័ន្ធអប់រំពេញលេញ និងឯកភាព

រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាព ដែលរួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ។ ការអប់រំកុមារតូចជាការសិក្សាត្រៀមនៃប្រព័ន្ធអប់រំ ។

ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំសាធារណៈ និងការអប់រំឯកជន ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ខ្លឹមសារស្ដីពីប្រព័ន្ធអប់រំក្នុងលិខិតបទដ្ឋានដោយឡែក ។

### មាត្រា ១៦.‒ ការគាំពារ និងការអប់រំកុមារតូច

រដ្ឋត្រូវគាំពារ និងអប់រំកុមារតូច ចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តទៅទារកដ្ឋាននៅសហគមន៍ ឬ នៅផ្ទះ ។

ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់ខ្លឹមសារស្ដីពីការគាំពារ និងការអប់រំកុមារតូច ។

### មាត្រា ១៧.‒ ការអប់រំចំណេះទូទៅ

ការអប់រំចំណេះទូទៅ ជាការចាំបាច់ដែលធ្វើឱ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយការលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញា កាយ និងធ្វើឱ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋាន ។

ការអប់រំចំណេះទូទៅជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សា និងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត ។

ការអប់រំចំណេះទូទៅរួមមាន ៖

-ការអប់រំបឋមសិក្សា ឬ ភូមិសិក្សាទី ១ ចាប់ពីថ្នាក់ទី ១ (មួយ) ដល់ថ្នាក់ទី ៦ (ប្រាំមួយ) នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬ ការអប់រំកម្រិតសមមូល

ការអប់រំបឋមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់ ដើម្បីឱ្យអ្នកសិក្សាអាចបន្តការសិក្សានៅមធ្យមសិក្សា

-ការអប់រំមធ្យមសិក្សា ឬ ភូមិសិក្សាទី ២ ចាប់ពីថ្នាក់ទី ៧ (ប្រាំពីរ) ដល់ថ្នាក់ទី ១២ (ដប់ពីរ) ។ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល ដំណាក់កាលទី ១ (មួយ)មធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី ៧(ប្រាំពីរ) ដល់ថ្នាក់ទី ៩(ប្រាំបួន) និង ដំណាក់កាលទី ២ (ពីរ) មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី ១០(ដប់) ដល់ថ្នាក់ទី ១២(ដប់ពីរ) ។

ការអប់រំមធ្យមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅឧត្តមសិក្សា ឬ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឬ ចូលរួមក្នុងជីវភាពសង្គម ។

ការអប់រំកម្រិតមូលដ្ឋាន ត្រូវកំណត់ ៩(ប្រាំបួន)ឆ្នាំ ចាប់ពីថ្នាក់ទី ១(មួយ)ដល់ថ្នាក់ទី ៩ (ប្រាំបួន)នៃការអប់រំចំណេះទូទៅក្នុងប្រព័ន្ធ ឬ ការអប់រំកម្រិតសមមូល ។

**មាត្រា ១៨.- ការអប់រំឧត្តមសិក្សា**

ការអប់រំឧត្តមសិក្សា ឬ ភូមិសិក្សាទី ៣ ជាការអប់រំកម្រិតក្រោយមធ្យមសិក្សា នៅគ្រឹះស្ថានឧត្តមសិក្សា ។

ការអប់រំឧត្តមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ និង ជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឱ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពសម្រាប់អភិវឌ្ឍប្រទេសជាតិ ។

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL

-៩-

ក្របខណ្ឌ និង លក្ខណៈនៃកម្រិតសញ្ញាបត្រ និងវិញ្ញាបនបត្រ ត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ ។ គ្រឹះស្ថានឧត្តមសិក្សាមាន ២ (ពីរ) ប្រភេទ សាកលវិទ្យាល័យ និងវិទ្យាស្ថាន ។

លក្ខណវិនិច្ឆ័យនៃប្រភេទគ្រឹះស្ថានឧត្តមសិក្សា និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ ។

**មាត្រា ១៩.- ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ**

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ គ្របដណ្ដប់គ្រប់ជំនាញ មុខរបរ និងបំណិន ដែលត្រូវផ្ដល់ឱ្យដោយគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ សាធារណៈ ឯកជន សហគ្រាស សហគមន៍ គ្រួសារ ឬ ដោយសហការរវាងគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ និងសហគ្រាស និង/ ឬ សហគមន៍ គ្រួសារ ។

**មាត្រា ២០.- ការបណ្ដុះបណ្ដាលបុគ្គលិកអប់រំ**

រដ្ឋត្រូវបណ្ដុះបណ្ដាលបុគ្គលិកអប់រំមុនពេល និង/ ឬ ក្នុងពេលកំពុងបម្រើការងារ ។

បុគ្គលិកអប់រំត្រូវឆ្លងកាត់ការបណ្ដុះបណ្ដាលគរុកោសល្យ ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ លើកលែងតែសាស្ត្រាចារ្យ និងបុគ្គលិកដែលបម្រើការក្នុងស្ថាប័នថ្នាក់ឧត្តមសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់កម្មវិធីគោល សម្រាប់ការបណ្ដុះបណ្ដាលបុគ្គលិកអប់រំ កំណត់កាយសម្បទា និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើសបុគ្គលិកអប់រំសាធារណៈ និងឯកជន ។

## ជំពូកទី ៥

## គុណភាព និងប្រសិទ្ធភាពអប់រំ

**មាត្រា ២១.- គុណភាព និងប្រសិទ្ធភាពអប់រំ**

រដ្ឋត្រូវលើកកម្ពស់គុណភាពអប់រំ ដើម្បីបំពេញសេចក្ដីត្រូវការខាងការសិក្សាជាមូលដ្ឋាន និងសេចក្ដីត្រូវការជំនាញ សម្រាប់ធ្វើឱ្យអ្នកសិក្សាមានសមត្ថភាព និងលទ្ធភាពចូលរួមអភិវឌ្ឍប្រទេសប្រកបដោយប្រសិទ្ធភាព ។

រដ្ឋត្រូវយកចិត្តទុកដាក់បំពាក់សម្ភារៈបច្ចេកទេសសមស្រប និងទំនើបក្នុងការរៀន និងបង្រៀន ដើម្បីធានាឱ្យបានគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ស្តង់ដារជាតិអប់រំ ស្តង់ដារជាតិបណ្តុះបណ្តាល និង/ឬ ស្តង់ដារជាតិសមត្ថភាព ត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។

**មាត្រា ២២.- យន្តការវាយតម្លៃគុណភាពអប់រំ**

គ្រឹះស្ថានសិក្សាត្រូវបំពេញស្តង់ដារជាតិអប់រំ ស្តង់ដារជាតិបណ្តុះបណ្តាល និង/ឬ ស្តង់ដារជាតិសមត្ថភាព ដើម្បីធានាបានគុណភាពអប់រំឱ្យបានប្រសើរឡើង ។

គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវបង្កើតយន្តការវាយតម្លៃផ្ទៃក្នុង ដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃគុណភាពនៃការអប់រំ និងលើកជាអនុសាសន៍អំពីវិធានការដែលគ្រឹះស្ថានសិក្សាត្រូវអនុវត្តបន្ត ។ យន្តការវាយតម្លៃផ្ទៃក្នុងនេះត្រូវបើកទូលាយឱ្យមានការចូលរួមពីសាធារណជន ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវបង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត ឬ ការបំពេញលក្ខខណ្ឌស្តង់ដារជាតិអប់រំរបស់គ្រឹះស្ថានសិក្សានានា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតយន្តការត្រួតពិនិត្យតាមដានលើការអនុវត្ត ឬ ការបំពេញលក្ខខណ្ឌស្តង់ដារសមត្ថភាពរបស់គ្រឹះស្ថានសិក្សាស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដើម្បីវាយតម្លៃគុណភាពអប់រំ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវចេញគោលការណ៍ណែនាំអំពីនីតិវិធីសម្រាប់ដំណើរការយន្តការពិនិត្យតាមដាន និងវាយតម្លៃ ។

**មាត្រា ២៣.- កម្មវិធីសិក្សា**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ជាក់លាក់នូវកម្មវិធីសិក្សាគោលសម្រាប់ការអប់រំចំណេះទូទៅ ដែលមានលក្ខណៈជាកាតព្វកិច្ចសម្រាប់អនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការអប់រំសីលធម៌ និងពលរដ្ឋវិជ្ជា ការអប់រំឱ្យចេះរួមរស់ជាមួយគ្នា ការអប់រំដើម្បីសន្តិភាព ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយចីរភាព ការអប់រំឱ្យចេះគោរពវប្បធម៌ផ្សេងៗ និងតម្លៃប្រពៃណី ត្រូវកំណត់ជាធាតុសំខាន់នៃកម្មវិធីសិក្សាគោល ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់ក្របខ័ណ្ឌលម្អិតនៃកម្មវិធីសិក្សាសម្រាប់អនុវត្តនៅគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ។

## មាត្រា ២៤.- ភាសាប្រើប្រាស់ក្នុងការបង្រៀន និងរៀន

ភាសាខ្មែរជាភាសាយាន និងជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាគោលនៅសាលារៀនចំណេះទូទៅសាធារណៈ ។

ចំពោះសាលារៀនចំណេះទូទៅឯកជន ត្រូវមានកម្មវិធីសិក្សាភាសាខ្មែរជាមុខវិជ្ជាគោលមួយនៃកម្មវិធីសិក្សារបស់ខ្លួន ។

ភាសាសម្រាប់ប្រើប្រាស់ចំពោះអ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានដើមកំណើតជាខ្មែរជនជាតិភាគតិច ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

ភាសាបរទេសដែលជាភាសាអន្តរជាតិ ត្រូវកំណត់ជាកំលាក់ជាមុខវិជ្ជាសិក្សាមួយសម្រាប់កម្មវិធីសិក្សាគោលនៃការអប់រំចំណេះទូទៅស្របតាមសេចក្តីត្រូវការរបស់អ្នកសិក្សា ។

## មាត្រា ២៥.- ការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល

ការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល ត្រូវអនុវត្តលើការវាស់ស្ទង់សមត្ថភាពសម្រាប់ការអប់រំចំណេះទូទៅ និងការវាស់ស្ទង់សមត្ថភាពសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងឧត្តមសិក្សា ។

ការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំស្របតាមគោលនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ។ បែបបទ និងនីតិវិធីនៃការវាស់នេះ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

## មាត្រា ២៦.- ការប្រឡង

ដើម្បីធានាបានគុណភាព និងប្រសិទ្ធភាពអប់រំប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ត្រូវមានការប្រឡង ។ គ្រប់ការប្រឡងជំនួស ឬ ការបន្លំគ្រប់រូបភាព ត្រូវបានហាម

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវទទួលខុសត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់ការប្រឡងនេះ ។

## ជំពូកទី ៦

## គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ

### មាត្រា ២៧.- ការកំណត់គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកសាងផែនការគោលសម្រាប់អភិវឌ្ឍវិស័យអប់រំ អនុលោមតាមគោលនយោបាយអប់រំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងការត្រួតពិនិត្យកែសម្រួលគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ ស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។

### មាត្រា ២៨.- វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ

រដ្ឋត្រូវលើកកម្ពស់ និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិតនិងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងស្របតាមសាកលភាវូបនីយកម្ម ដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍប្រទេសជាតិ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់គោលការណ៍ស្តីពីវិទ្យាសាស្ត្រ និងបច្ចេក-វិទ្យាសម្រាប់ការអប់រំគ្រប់ភូមិសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

### មាត្រា ២៩.- ភាពជាដៃគូសម្រាប់ការអប់រំ

រដ្ឋត្រូវបើកទូលាយឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់មានជាអាទិ៍ ផ្នែកសាធារណៈ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ នៅក្នុងដំណើរការនៃការអភិវឌ្ឍការតាក់តែង ការតាមដានវាយតម្លៃលើការអនុវត្ត ការលើកសំណើឱ្យពិនិត្យឡើងវិញ និងសំណើកែលម្អ គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រជាតិអប់រំ ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

រដ្ឋលើកទឹកចិត្ត និងគាំទ្រដល់ស្ថាប័នឯកជន ដើម្បីបង្កើតភាពជាដៃគូក្នុងការផ្តល់សេវាអប់រំគ្រប់ប្រភេទ និងគ្រប់កម្រិត ។

**មាត្រា ៣០.- អាហារូបករណ៍ និងឧបត្ថម្ភធន**

រដ្ឋត្រូវកំណត់គោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ ឧបត្ថម្ភធននិងឥណទានសម្រាប់អ្នកសិក្សា ។

រដ្ឋលើកទឹកចិត្តចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គលដែលផ្តល់អាហារូបករណ៍ ឬ ឧបត្ថម្ភធនសម្រាប់អ្នកសិក្សា ។

## ជំពូកទី ៧
## សិទ្ធិ និងករណីយកិច្ចអប់រំ

**មាត្រា ៣១.- សិទ្ធិទទួលការអប់រំ**

ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច ៩(ប្រាំបួន)ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងវិធានការជាជំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣២.- សិទ្ធិចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១ (មួយ) នៃកម្មវិធីអប់រំចំណេះទូទៅ**

ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១(មួយ) នៃកម្មវិធីអប់រំចំណេះទូទៅក្នុងប្រព័ន្ធត្រូវបានកំណត់ចំពោះកុមារ ដែលមានអាយុចាប់ពី៦ (ប្រាំមួយ)ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០(ចិតសិប)ខែឡើងទៅ នៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន ។

**មាត្រា ៣៣.- សិទ្ធិ សេរីភាពខាងជំនឿសាសនានៅក្នុងការអប់រំ**

រដ្ឋគោរពសិទ្ធិ សេរីភាពខាងជំនឿសាសនា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។ គ្រប់ការបង្ខំឱ្យអ្នកសិក្សា និងអ្នកពាក់ព័ន្ធការអប់រំឱ្យចូលរួមក្នុងសកម្ម-

ភាពសាសនា និង/ ឬ ការប្រតិបត្តិសាសនាណាមួយដែលជាផ្នែកនៃការអប់រំ ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី ត្រូវហាមឃាត់ ។

ការសិក្សាអំពីសាសនានៅក្នុងកម្មវិធីសិក្សា ត្រូវបានអនុញ្ញាតសម្រាប់តែការយល់ដឹងទូទៅប៉ុណ្ណោះ ។

**មាត្រា ៣៤.- សកម្មភាពនយោបាយក្នុងស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា**

ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវគោរពគោលការណ៍អព្យាក្រឹតភាព ។

ការធ្វើសកម្មភាពនយោបាយ និង/ ឬ ការឃោសនានយោបាយឱ្យគណបក្សនយោបាយណាមួយក្នុងស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវហាមឃាត់ ។

**មាត្រា ៣៥.- សិទ្ធិ និងករណីយកិច្ចរបស់អ្នកសិក្សា**

សិទ្ធិរបស់អ្នកសិក្សាទាក់ទងនឹងការអប់រំមានដូចតទៅ :

- សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី
- សិទ្ធិមានសេរីភាពខាងការសិក្សា
- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព
- សិទ្ធិប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬ ក្លឹបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ
- សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្តីពីការអប់រំ
- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន
- សិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សជាពិសេសសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬ ការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ។

ករណីយកិច្ចរបស់អ្នកសិក្សាមានដូចតទៅ :

- គោរពបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រដោយអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-ខិតខំសិក្សាឱ្យអស់ពីលទ្ធភាពរបស់ខ្លួន ដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្ដីថ្លៃថ្នូរ ។

**មាត្រា ៣៦.- សិទ្ធិ និងករណីយកិច្ចរបស់មាតាបិតា ឬ អ្នកអាណាព្យាបាល**

សិទ្ធិរបស់មាតាបិតា ឬ អ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជន ដែលស្ថិតក្នុងបន្ទុកមានដូចតទៅ :

-សិទ្ធិក្នុងការជ្រើសរើសកម្មវិធីអប់រំ និងគ្រឹះស្ថានសិក្សា សម្រាប់អ្នកសិក្សាឱ្យចូលសិក្សា

-សិទ្ធិទទួលបានព័ត៌មាន និងរបាយការណ៍នៃការសិក្សាពីគ្រឹះស្ថានសិក្សារបស់អ្នកសិក្សា ដែលស្ថិតក្នុងបន្ទុក

-សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញ នៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់សាលារៀន និងថ្នាក់ជាតិ ដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន ។

ករណីយកិច្ចមាតាបិតា ឬ អ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជនដែលស្ថិតក្នុងបន្ទុក :

-នាំកុមារដែលមានអាយុចាប់ពី ៦ (ប្រាំមួយ) ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ (ចិតសិប) ខែ ឡើងទៅចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១ នៃកម្មវិធីអប់រំចំណេះទូទៅនៅសាលារៀន ដែលមានអាជ្ញាប័ណ្ណអប់រំ

-ខិតខំឱ្យអស់លទ្ធភាព ដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សាជាពិសេសចំពោះការអប់រំកម្រិតមូលដ្ឋាន

-យកចិត្តទុកដាក់ផ្សារភ្ជាប់សាលា គ្រួសារ និងសហគមន៍ ដើម្បីចូលរួមជួយបណ្ដុះបណ្ដាល និងកែលម្អបរិស្ថានសិក្សា ។

**មាត្រា ៣៧.- សិទ្ធិ និងភារកិច្ចរបស់បុគ្គលិកអប់រំ**

សិទ្ធិរបស់បុគ្គលិកអប់រំមានដូចតទៅ :

-សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម

-សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ

-សិទ្ធិបង្កើត ឬ ចូលរួមក្នុងសមាគមបុគ្គលិកអប់រំ ឬ សមាគមវិជ្ជាជីវៈផ្សេងៗ តាមច្បាប់កំណត់ជាធរមាន

-សិទ្ធិរៀបចំការប្រជុំលើការងារអប់រំ ជាសាធារណៈ

-សិទ្ធិចូលរួមនៅក្នុងកិច្ចការនយោបាយតាមច្បាប់កំណត់

-សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន

-សិទ្ធិទទួលសេវាអប់រំផ្សេងទៀតប្រកបដោយសមធម៌ និងសិទ្ធិផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ។

កាតព្វកិច្ចរបស់បុគ្គលិកអប់រំ :

-គោរពក្រមសីលធម៌វិជ្ជាជីវៈ

-បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ជាធរមាន

-អនុវត្ត និងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ។

បុគ្គលិកអប់រំឯកជនមានសិទ្ធិ និងកាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងច្បាប់ស្តីពីការងារជាធរមាន ។

**មាត្រា ៣៨.- ការអប់រំពិសេស**

រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការអប់រំពិសេស សម្រាប់ជនពិការ និង អ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/ឬ បញ្ញាខ្ពស់ ។

ការអប់រំពិសេស ផ្តល់ចំពោះអ្នកសិក្សាពូកែឱ្យស្របតាមបញ្ញា និងទេពកោសល្យរបស់អ្នកសិក្សានោះ និងផ្តល់លទ្ធភាពឱ្យអ្នកសិក្សាពិការអាចសិក្សាបានដោយសមរម្យ ។

កម្មវិធីអប់រំពិសេស ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

**មាត្រា ៣៩.- សិទ្ធិរបស់អ្នកសិក្សាពិការ**

អ្នកសិក្សាពិការមានសិទ្ធិដូចអ្នកសិក្សាមិនពិការដែរ និងមានសិទ្ធិពិសេសដោយឡែកផ្សេងទៀត :

-អ្នកសិក្សាពិការទាំងពីរភេទមានសិទ្ធិសិក្សាជាមួយសិស្ស ឬ និស្សិតទូទៅបាន ប្រសិនបើមានការសម្របសម្រួលសមស្របក្នុងដំណើរការសិក្សា ដែលអ្នកសិក្សាពិការនោះអាចបំពេញកម្មវិធីសិក្សារបស់គ្រឹះស្ថានសិក្សានោះបាន

-អ្នកសិក្សាពិការដែលមានសេចក្តីត្រូវការពិសេស មានសិទ្ធិទទួលបានការ

បង្រៀនបន្ថែមនៅក្នុងកម្មវិធីសិក្សាធម្មតា ដែលមិនមែនតាមកម្មវិធីសិក្សាពិសេសដោយឡែកទេ

-អ្នកសិក្សាពិការដែលមិនមានលទ្ធភាពចូលសិក្សាជាមួយសិស្ស ឬ និស្សិតទូទៅបាន មានសិទ្ធិទទួលបានការអប់រំពិសេសនៅក្នុងថ្នាក់រៀនពិសេសដោយឡែក ។ អ្នកសិក្សាពិការទាំងនេះ អាចចូលសិក្សានៅសាលារៀនក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនបាន ។

## មាត្រា ៤០.- សិទ្ធិស្នើ សិទ្ធិតវ៉ា សិទ្ធិប្ដឹង និងសិទ្ធិទទួលបានដំណោះស្រាយ

មាតាបិតា ឬ អ្នកអាណាព្យាបាល អ្នកសិក្សា និងបុគ្គលិកអប់រំដែលត្រូវបានគេបំពានសិទ្ធិដូចមានចែងក្នុងច្បាប់នេះមានសិទ្ធិស្នើ ឬ តវ៉ាទៅអាជ្ញាធរអប់រំមានសមត្ថកិច្ចតាមឋានានុក្រម ព្រមទាំងសិទ្ធិប្ដឹងទៅតុលាការ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវចេញលិខិតបទដ្ឋាន ស្ដីពីនីតិវិធីនៃការស្នើ ឬការតវ៉ា និងនីតិវិធីនៃដំណោះស្រាយនេះ ។

## មាត្រា ៤១.- សិទ្ធិរបស់អ្នកសិក្សា និងបុគ្គលិកអប់រំក្នុងការត្រួតពិនិត្យសុខភាព

អ្នកសិក្សា និងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាប័ណ្ណអប់រំ មានសិទ្ធិទទួលបាននូវការពិនិត្យសុខភាព ។

គោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យសុខភាពនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួងទទួលបន្ទុកវិស័យសុខាភិបាល ។

## មាត្រា ៤២.- សិទ្ធិផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំ

គ្រប់ខ្លឹមសារផ្សព្វផ្សាយ ឃោសនា ព័ត៌មានអប់រំ ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យអប់រំ ។ គ្រប់ការបន្លំបោកប្រាស់ទោះជាតាមរូបភាពណាក៏ដោយ ត្រូវហាមឃាត់ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្ដីពីការផ្សព្វផ្សាយ ឃោសនាព័ត៌មានអប់រំនេះ ។

## មាត្រា ៤៣.- សិទ្ធិទទួលបានព័ត៌មានអប់រំ

ព័ត៌មានអប់រំនៃគ្រប់ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មានដែលទាក់ទងនឹងរូបវន្តបុគ្គល ។ ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវផ្ដល់ព័ត៌មាន [illegible] ឱ្យទៅអ្នកដែលមានផលប្រយោជន៍តាមការស្នើសុំ ។

បែបបទស្តីពីការផ្តល់ព័ត៌មានអប់រំ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

## ជំពូកទី ៨
## ធនធានសម្រាប់ការអប់រំ

**មាត្រា ៤៤.- ការចូលរួម ការកៀរគរ និងការគ្រប់គ្រងធនធានសម្រាប់ការអប់រំ**

រដ្ឋត្រូវជំរុញ នឹងផ្តល់ការលើកទឹកចិត្ត ចំពោះសប្បុរសជន តាមភាពសមស្រប និងចាំបាច់ ដោយទទួលស្គាល់ការអប់រំជាការវិនិយោគមួយដ៏ល្អបំផុត ។

បុគ្គល បុព្វជិត គ្រួសារ សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និង ឯកជនទាំងអស់ មានសិទ្ធិចូលរួម និង ផ្តល់ធនធានយ៉ាងពេញលេញទាំងធនធានមនុស្សទាំងសម្ភារៈ ឬ ថវិកា ក្នុងគោលបំណងដើម្បីគាំទ្រនិងអភិវឌ្ឍវិស័យអប់រំ ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភព ដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា ។ ការផ្តល់ធនធានត្រូវធ្វើតាមការស្ម័គ្រចិត្ត និងឥតលក្ខខណ្ឌ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវធានានូវតម្លាភាព និងការទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រភពធនធាននៃការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអប់រំ ។

**មាត្រា ៤៥.- ការចុះកិច្ចសន្យា និង ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ**

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និងរូបវន្តបុគ្គលមានសិទ្ធិចុះកិច្ចសន្យា ឬ កិច្ចព្រមព្រៀងជាមួយអ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីចូលរួមអភិវឌ្ឍវិស័យអប់រំ ។ រាល់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងត្រូវធ្វើឡើងស្របតាមច្បាប់ និងត្រូវបម្រើផលប្រយោជន៍របស់គ្រឹះស្ថានសិក្សា ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការប្រើប្រាស់ធនធានទាំងអស់ ដើម្បីជាផលប្រយោជន៍ដល់គ្រឹះស្ថានសិក្សា ។

បែបបទ និងនីតិវិធីនៃការចុះកិច្ចសន្យា ឬ កិច្ចព្រមព្រៀងត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៤៦.- ការបង្កើតគ្រឹះស្ថានសិក្សាដោយគ្មានអាជ្ញាប័ណ្ណ**

អំពើបង្កើត ឬ បើកឱ្យដំណើរការនូវគ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលដោយគ្មានអាជ្ញាប័ណ្ណអប់រំជាមុន ដូចមានបញ្ញត្តិនៅក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

**មាត្រា ៤៧.- ការប្រើប្រាស់ប្រភេទគ្រឹះស្ថានសិក្សាមិនសមស្រប**

គ្រប់អំពើប៉ះពាល់ដល់ការប្រើប្រាស់ប្រភេទគ្រឹះស្ថានសិក្សា ដែលផ្ទុយនឹងបេសកកម្មអប់រំរបស់ខ្លួនដូចមានបញ្ញត្តិក្នុងមាត្រា ១២ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ហើយត្រូវព្យួរជាបណ្តោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់គ្រឹះស្ថានសិក្សាទាំងនោះ ។

**មាត្រា ៤៨.- បទល្មើសពាក់ព័ន្ធនឹងការផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រ**

គ្រប់ការផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រ ដែលមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ១៤ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន)រៀល និងដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី)ឆ្នាំ ។

**មាត្រា ៤៩.- ការបន្លំក្នុងការប្រឡង**

សាមីខ្លួន ឬ ជនណាដែលប្រឡងជំនួស ឬ បន្លំគ្រប់រូបភាពក្នុងការប្រឡងដូចបានបញ្ញត្តិក្នុងមាត្រា ២៦ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ROYAUME DU CAMB… LE MINISTRE DU PALAIS

ក្នុងករណីមិនរាងចាល សាមីខ្លួនត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដង នៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ហើយត្រូវលុបការប្រឡងសម្រាប់រយៈពេល ២(ពីរ)ឆ្នាំ ឬ ហាមឃាត់មិនឱ្យចុះឈ្មោះក្នុងបញ្ជីប្រឡងជាស្ថាពរ ។ ចំពោះជនដែលប្រឡងជំនួស ឬ បន្លំគ្រប់រូបភាពក្នុងការប្រឡង ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៥០.- បទល្មើសពាក់ព័ន្ធនឹងដំណើរការនៃការប្រឡង**

គ្រប់ទង្វើដែលប្រព្រឹត្តឡើងដោយបុគ្គលិកអប់រំ មានភាពមិនត្រឹមត្រូវក្នុងដំណើរការនៃការប្រឡងដូចបានបញ្ញត្តិក្នុងមាត្រា ២៦ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ចំពោះបុគ្គលិកអប់រំសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី ១ ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។ ចំពោះបុគ្គលិកអប់រំសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ បន្ថែមទៀត ។ ចំពោះបុគ្គលិកអប់រំឯកជន ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៥១.- ការប៉ះពាល់ដល់សេរីភាពខាងជំនឿសាសនាក្នុងការអប់រំ**

គ្រប់អំពើប៉ះពាល់ដល់សេរីភាពខាងជំនឿសាសនាក្នុងការអប់រំ ដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល និងដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១(មួយ)ឆ្នាំ ។

**មាត្រា ៥២.- ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សា**

គ្រប់សកម្មភាពនយោបាយ ឬ ការឃោសនានយោបាយ ឱ្យគណបក្សនយោបាយណាមួយនៅក្នុងស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សាដែលផ្ទុយនឹងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

ROYAUME DU CAMBODGE ... REGISTRE DU PALAIS ROYAL

ចំពោះនីតិបុគ្គលត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដង នៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

បើអំពើដូចបានកំណត់នៅក្នុងវាក្យខ័ណ្ឌទី ១ ខាងលើ ប្រព្រឹត្តដោយនីតិបុគ្គលដែលជាស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សា ហើយស្ថិតក្នុងករណីមិនរាងចាល ត្រូវលុបជាបណ្ដោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់ស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សានោះ ។

**មាត្រា ៥៣.- ការផ្សព្វផ្សាយ និង ការឃោសនាព័ត៌មានអប់រំខុសច្បាប់**

គ្រប់អំពើផ្សព្វផ្សាយ ឬ ឃោសនាព័ត៌មានអប់រំដោយគ្មានការអនុញ្ញាត ឬ ដោយបន្លំបោកប្រាស់តាមរូបភាពណាក៏ដោយ ដែលផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។ នីតិបុគ្គលដែលជាស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សា ត្រូវលុបជាបណ្ដោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំ ។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

**មាត្រា ៥៤.- បញ្ញត្តិអន្តរកាល**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សាណា ដែលកំពុងដំណើរការខុសពីបញ្ញត្តិនៃច្បាប់នេះ ត្រូវបំពេញបែបបទឱ្យបានត្រឹមត្រូវក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

ចរល.០៧១២.៦២៤ **ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
**ហត្ថលេខា**
**គុល ផេង**

លេខ: ៥៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

## ឧបសម្ព័ន្ធ

**ភារកិច្ចស្វ័យកិច្ច** : សំដៅដល់កិច្ចការដែលត្រូវតែធ្វើតាមវិធានច្បាប់ដែលបានចែង ។

**ក្រសួងទទួលបន្ទុកវិស័យអប់រំ:** សំដៅដល់ស្ថាប័នសាធារណៈណាមួយដែលទទួលខុសត្រូវលើវិស័យអប់រំ ទោះជាស្ថាប័ននោះ ទទួលបន្ទុកការងារផ្សេងទៀតក៏ដោយ ។ ការប្រើពាក្យបែបនេះ គឺដើម្បីដៅឱ្យចំស្ថាប័នមួយ ដែលទទួលបន្ទុកកិច្ចការអប់រំដែលជាធម្មតាមានការផ្លាស់ប្តូរឈ្មោះតាមអាណត្តិរបស់រាជរដ្ឋាភិបាល ។

**ភារកិច្ច:** សំដៅដល់ចំណងតាមផ្លូវច្បាប់ ដែលបង្ខំឱ្យត្រូវតែធ្វើ ។

**ការអប់រំក្នុងប្រព័ន្ធ** :សំដៅដល់ដំណើរការសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និង ហ្មត់ចត់ មានរចនាសម្ព័ន្ធរៀបរយ និងតាមលំដាប់ថ្នាក់ ។ ការអប់រំក្នុងប្រព័ន្ធផ្តល់ឱ្យដោយគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាបណ្ណអប់រំត្រឹមត្រូវ ឬ ដែលមានការទទួលស្គាល់គុណភាពអប់រំស្រប តាមលក្ខខណ្ឌផ្នែកច្បាប់ និងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

**ការអប់រំក្រៅប្រព័ន្ធ:** សំដៅដល់សកម្មភាពអប់រំ ដែលមានការរៀបចំមានលក្ខណៈជាប្រព័ន្ធ ដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌនៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ការសិក្សាមួយចំនួនដែលបានជ្រើសរើស ។ ការអប់រំក្រៅប្រព័ន្ធគ្របដណ្តប់លើកម្មវិធីអប់រំជាច្រើន ដូចជា អក្ខរកម្ម បំណិនជីវិត បំណិនការងារ ការអប់រំមូលដ្ឋាន សម្រាប់អ្នកសិក្សាដែលមិនចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ ដែលមានលក្ខណៈជាការសិក្សាបន្ត និងការសិក្សាកម្រិតសមមូលសម្រាប់ការបញ្ចូលទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬ ជាការអប់រំអស់មួយជីវិត ។ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានសិទ្ធិសុំ និងទទួលបាននូវការធ្វើតេស វាយតម្លៃកម្រិតសមមូលចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

**ការអប់រំមិនផ្លូវការ:** សំដៅដល់ដំណើរការស្វ័យសិក្សា ឬ ការសិក្សាដោយខ្លួនឯង និងជាដំណើរការសិក្សាអស់មួយជីវិត តាមការចាប់អារម្មណ៍ សក្តានុពលការត្រៀមខ្លួនជាស្រេច និងឱកាសដែលមាន ហើយដែលអ្នកសិក្សាទទួល និងបង្កើនផ្តល់ចំណេះដឹង ជំនាញ ឥរិយា-

ROYAUME DU CAMBODGE ... MINISTÈRE ... ROYAL

បថ និងគំនិតបានមកពីបទពិសោធប្រចាំថ្ងៃពីការងារ ការសំដែង និងពីជីវិតផ្ទាល់ និងជាការសិក្សាតាមរយៈមនុស្ស សង្គម មជ្ឈដ្ឋានជុំវិញប្រព័ន្ធសារព័ត៌មាន ព្រមទាំងប្រភពចំណេះដឹង ឬ ប្រភពព័ត៌មានផ្សេងទៀតនៅពេលណា និង នៅទីកន្លែងណាផ្សេងទៀតក៏ដោយក្រៅពីកម្មវិធីអប់រំក្នុងប្រព័ន្ធ និងកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ អ្នកសិក្សាមានសិទ្ធិសុំ និងទទួលការធ្វើតេស្តវាយតម្លៃកម្រិតសមមូល ចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ច ដូចមានចែងក្នុងច្បាប់នេះ ។

**ការអប់រំសម្រាប់ទាំងអស់គ្នា** : សំដៅដល់ចលនារបស់ពិភពលោក ដើម្បីឱ្យកុមារ យុវជន និងជនពេញវ័យគ្រប់រូប មានសិទ្ធិទទួលផលប្រយោជន៍ពីការអប់រំបានយ៉ាងពេញលេញ និងប្រកបដោយគុណភាពខ្ពស់ ។

**ការអប់រំមានគុណភាព** : សំដៅដល់ការអប់រំមួយ ដែលបំពេញបានសេចក្តីត្រូវការនៃការសិក្សាជាមូលដ្ឋាន និងបន្តអស់មួយជីវិតរបស់អ្នកសិក្សា ។

**កម្មវិធីសិក្សា** : សំដៅដល់សំណុំមុខវិជ្ជា ដែលត្រូវបានរៀបចំឱ្យអ្នកសិក្សា ទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**កម្មវិធីសិក្សាគោល**: សំដៅដល់កម្មវិធីសិក្សាដែលកំណត់ដោយអាជ្ញាធរអប់រំមានសមត្ថកិច្ចសម្រាប់ឱ្យគ្រឹះស្ថានសិក្សា ត្រូវតែអនុវត្តតាមកម្មវិធីនេះជាដាច់ខាត ។

**ការអប់រំពិសេស** : សំដៅដល់ការអប់រំបណ្តុះបណ្តាល ដើម្បីផ្តល់ដល់ជនដែលមានតម្រូវការពិសេសដូចជាជនពិការ និងអ្នកសិក្សាពូកែមានបញ្ញាខ្ពស់ ។

**ការបន្លំបោកប្រាស់ក្នុងការអប់រំ** : សំដៅដល់ការសូកប៉ាន់ ការទទួលសំណូក ការក្លែងបន្លំគ្រប់រូបភាព ក្នុងដំណើរការអប់រំ មានជាអាទិ៍ ការទិញលក់សញ្ញាបត្រ ឬវិញ្ញាបនបត្រ វិញ្ញាសាប្រឡងថ្នាក់ជាតិ និងវិញ្ញាសាតេស្តវាស់ស្ទង់ការអប់រំកម្រិតសមមូល ឬ ការប្រឡងជំនួស ។

**គ្រឹះស្ថានសិក្សា** : សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាបណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬ សាកលវិទ្យាល័យ ឬ មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ។

**គ្រឹះស្ថានឧត្តមសិក្សា** : សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាដែលផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញឯកទេសកម្រិតក្រោយមធ្យមសិក្សា ។

**បំណិនជីវិត** : សំដៅដល់ចំណេះដឹងដែលផ្តោតលើសុខភាព ការបង្ការទប់ស្កាត់ អាហារូបត្ថម្ភ ការយល់ដឹងពីកិច្ចការពលរដ្ឋ និងបរិស្ថាន ជំនាញសង្គម និងជំនាញក្នុងការប្រាស្រ័យទាក់ទងគ្នារបស់អ្នកសិក្សា ។

**បុគ្គលិកអប់រំ** : សំដៅដល់មន្ត្រី ដែលកំពុងបម្រើការក្នុងវិស័យអប់រំ និងបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ និងសាស្ត្រាចារ្យដែលបម្រើការនៅឧត្តមសិក្សា ។ បុគ្គលិកអប់រំរួមមានបុគ្គលិកបង្រៀន ឬ មិនបង្រៀនក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ឬ បុគ្គលិកបម្រើការក្នុងវិស័យអប់រំឯកជនគ្រប់លំដាប់ថ្នាក់ លើកលែងតែមន្ត្រីនយោបាយដែលកំពុងដឹកនាំវិស័យអប់រំក្នុងក្រសួងស្ថាប័នរដ្ឋ ។

**ភាសាអន្តរជាតិ** : សំដៅដល់ភាសាបរទេសទាំងឡាយណា ដែលត្រូវបានគេនិយមប្រើប្រាស់ច្រើនជាងគេលើឆាកអន្តរជាតិ ។

**វិទ្យាស្ថាន** : សំដៅដល់គ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់ការអប់រំ តាមរយៈមុខជំនាញសិក្សាមួយ ឬ ច្រើន ។

**គ្រឹះស្ថានសិក្សាសាធារណៈ** : សំដៅដល់ស្ថាប័នអប់រំដែលគ្រប់គ្រងដោយអាជ្ញាធរអប់រំសាធារណៈ ឬ ដោយភ្នាក់ងាររដ្ឋ ឬ ដោយក្រុមប្រឹក្សាភិបាល ឬ ក្រុមប្រឹក្សាសាលារៀនដែលមានសមាជិកភាគច្រើនត្រូវបានតែងតាំងដោយអាជ្ញាធរសាធារណៈ ឬ ត្រូវបានបោះឆ្នោតជ្រើសរើស ។

**គ្រឹះស្ថានសិក្សាឯកជន** ៖ សំដៅដល់ស្ថាប័នអប់រំ ដែលគ្រប់គ្រងដោយបុគ្គលឯកជន ឬ ដោយក្រុមប្រឹក្សាភិបាលឯកជន ឬ ក្រុមប្រឹក្សាសាលារៀនឯកជន ។

**សាកលវិទ្យាល័យ**៖ សំដៅដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានបេសកកម្មផ្តល់ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស ចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ ។ សាកលវិទ្យាល័យមានមហាវិទ្យាល័យច្រើនជាចំណុះ ដែលក្នុងនោះត្រូវមានមហាវិទ្យាល័យ ៣ ជាចាំបាច់គឺ មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រនិងភាសា មហាវិទ្យាល័យគណិតសាស្ត្រនិងវិទ្យាសាស្ត្រ និងមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងយ៉ាងតិចត្រូវមានមហាវិទ្យាល័យបន្ថែមពីរផ្សេងទៀត ។

**សិទ្ធិទទួលនៃអាជ្ញាប័ណ្ណអប់រំ**៖ សំដៅដល់អ្នកទទួលសិទ្ធិពាក់ព័ន្ធលើផលប្រយោជន៍នៃអាជ្ញាប័ណ្ណអប់រំ តាមរយៈការផ្ទេរសិទ្ធិ ការលក់ ឬ ការស្នងមរតកជាដើម ។

**ស្ថាប័នអប់រំ** ៖ សំដៅដល់ស្ថាប័នដែលមានគោលបំណងផ្តល់សេវាអប់រំ ។ ស្ថាប័នអប់រំមានស្ថាប័នអប់រំសាធារណៈ និងស្ថាប័នអប់រំឯកជន ។

**ស្ថាប័នអប់រំសាធារណៈ**៖ សំដៅដល់ស្ថាប័នអប់រំ ដែលគ្រប់គ្រងដោយអាជ្ញាធរអប់រំ សាធារណៈ ឬ ក្រសួងស្ថាប័នរដ្ឋ ។

**ស្ថាប័នអប់រំឯកជន** ៖ សំដៅដល់ស្ថាប័នអប់រំ ដែលដំណើរការគ្រប់គ្រងដោយបុគ្គលឯកជន សមាគម ឬ អង្គការក្រៅរដ្ឋាភិបាល។

**ស្តង់ដារជាតិអប់រំ** ៖ សំដៅដល់លក្ខណៈវិនិច្ឆ័យអប្បបរមាសម្រាប់វាយតម្លៃកម្រិតអប់រំនៃប្រព័ន្ធអប់រំ ។

**ស្តង់ដារជាតិបណ្តុះបណ្តាល** ៖ សំដៅដល់លក្ខណៈវិនិច្ឆ័យអប្បបរមាសម្រាប់វាយតម្លៃកម្រិតនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**ស្តង់ដារជាតិសមត្ថភាព** ៖ សំដៅដល់លក្ខណៈវិនិច្ឆ័យអប្បបរមា សម្រាប់វាយតម្លៃសមត្ថភាពរបស់សិក្ខាកាម ដែលទទួលបានពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**អាជ្ញាប័ណ្ណអប់រំ** : សំដៅដល់លិខិតអនុញ្ញាត ដែលចេញដោយអាជ្ញាធរអប់រំសាធារណៈដើម្បីផ្តល់សិទ្ធិឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាអ្នកគ្រប់គ្រង ឬ ម្ចាស់កម្មសិទ្ធិនៃគ្រឹះស្ថានសិក្សាអាចដំណើរការសកម្មភាពអប់រំរបស់ខ្លួនដោយស្របច្បាប់បាន ។

**អ្នកកាន់អាជ្ញាប័ណ្ណអប់រំ** : សំដៅដល់បុគ្គលដែលទទួលបានសិទ្ធិអនុញ្ញាតឱ្យដំណើរការសកម្មភាពអប់រំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចស្របតាមនីតិវិធីច្បាប់ជាធរមាន។

**អ្នកសិក្សាពិការ** : សំដៅដល់អ្នកសិក្សាពិការ ដែលទទួលបានការសម្របសម្រួលក្នុងការអប់រំ ។ អ្នកសិក្សាពិការទាំងនោះរួមមានពិការ ជើងម្ខាង ឬ ទាំងសងខាង ថ្លង់ គរ ឬ ពិការភ្នែកទាំងសងខាង និងពិការផ្នែកស្មារតី ។

**អាហារូបករណ៍** : សំដៅដល់ប្រាក់ដែលផ្តល់ឱ្យអ្នកសិក្សា ដើម្បីទំនុកបម្រុងការសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ ។

**ឧបត្ថម្ភធន** : សំដៅដល់ប្រាក់ឧបត្ថម្ភជួយទំនុកបម្រុងផ្នែកណាមួយដែលជាកង្វះខាតខាងជីវភាពរបស់អ្នកសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ ។

**ឥណទានសិក្សា** : សំដៅដល់ប្រាក់កម្ចី ដែលរដ្ឋអនុញ្ញាតឱ្យអ្នកសិក្សាខ្ចី ដើម្បីបំពេញតម្រូវការក្នុងផ្នែកណាមួយដែលខ្វះខាតក្នុងរយៈពេលសិក្សា ហើយប្រាក់ដែលខ្ចីនេះ ត្រូវសងជូនរដ្ឋវិញក្នុងពេលកំណត់ណាមួយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL